**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ៣៦៤៤/២៤ កសក.អល

ថ្ងៃព្រហស្បតិ៍ ១០កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧.
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤.

**ជម្រាបមក**

**លោកប្រធានក្រុមហ៊ុន ខេ ខេ អេស ១៥៣ ឯ.ក**

**កម្មវត្ថុ** ៖ ការចុះកិច្ចសន្យាស្ដីពីការផ្គត់ផ្គង់ថ្នាំចាក់ការពារ និងព្យាបាលសត្វ ប្រចាំឆមាសទី១ ឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ។

**យោង** ៖ លិខិតលេខ៣១៦៤/២៤...កសក.អល ចុះថ្ងៃទី០១.....ខែមេសា ឆ្នាំ២០២៤ ស្ដីពីការសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យា ស្ដីពីការផ្គត់ផ្គង់ថ្នាំចាក់ការពារ និងព្យាបាលសត្វ ប្រចាំឆមាសទី១ ឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូម **លោកប្រធាន** អញ្ជើញមកចុះកិច្ចសន្យាស្ដីពីការផ្គត់ផ្គង់ថ្នាំចាក់ការពារ និងព្យាបាលសត្វ ប្រចាំឆមាសទី១ ឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នៅអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេល០៧ថ្ងៃ (ប្រាំពីរថ្ងៃ) យ៉ាងយូរបន្ទាប់ពីបានទទួលលិខិតនេះ ដោយភ្ជាប់មកជាមួយនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬធនាគារពាណិជ្ជណាមួយដែលបានចុះអនុស្សរណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានតម្លៃទឹកប្រាក់ស្មើនឹង១០% (ដប់ភាគរយ) នៃតម្លៃកិច្ចសន្យា។

អាស្រ័យហេតុនេះ សូម **លោកប្រធាន** ចាត់ចែងតាមខ្លឹមសារខាងលើតាមការគួរ។

សូម **លោកប្រធាន** ទទួលនូវការរាប់អានពីខ្ញុំ។

**ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**គឹម សុន**

**ចម្លងជូន៖**
-អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
"ដើម្បីជ្រាប"
-ឯកសារ កាលប្បវត្តិ